ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៧ លេខ ៨៥ សប្តាហ៍ទី ៣ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

348.033
CAM

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសំរេច សារាចរ ប្រកាស

ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៧០ ស្ដីពីការតែងតាំងបន្តថ្នាក់ដឹកនាំការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ ៩២៥៣

១៥-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៧១ ស្ដីពីការតែងតាំងឯកឧត្តម ពេជ្រ សំណាង ជាទីប្រឹក្សាផ្ទាល់ សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ៩២៥៥

១៩-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៧៥ ស្ដីពីការតម្លើងឋានៈឯកឧត្តម ម៉ុន ទី ជាអគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បន្ថែមលើមុខងារបច្ចុប្បន្ន ៩២៥៦

១៩-១១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/១១០៧/៩៧៦ ស្ដីពីការតែងតាំងឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ៩២៥៧

១៩-១១-២០០៧ -ព្រះរាជក្រឹត្យនស/រកត/១១០៧/៩៧៧ ស្ដីពីការតែងតាំងឯកឧត្តម ចំនួន ០៩ រូប ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប និង ០៨ រូបជាអគ្គលេខាធិការ,ជាអគ្គលេខាធិការរងនៃអាជ្ញាធរអាងទន្លេសាប ៩២៥៨

II.ក្រុមប្រឹក្សាធម្មនុញ្ញ

១.សេចក្ដីសំរេច

១៦-១១-២០០៧ -សេចក្ដីសំរេច លេខ ០៩៣/004/២០០៧ កបធ.ច ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០៧ ៩២៦០

២.សេចក្ដីជូនដំណឹង

១៤-១១-២០០៧ -សេចក្ដីជូនដំណឹង លេខ ០០៣/០១/២០០៧ កបធ.សជណ ស្ដីពីសំណើសុំពិនិត្យធម្មនុញ្ញភាពផ្លូវច្បាប់រវាងខ្លឹមសារលិខិតលេខ៥៨៨ស.ជ.ណ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងសាលដីកាស្ថាពររបស់តុលាការកំពូល ៩២៦២

III-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៤-១១-២០០៧ -អនុក្រឹត្យ លេខ ៩១៧ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥២៦៣

១៤-១១-២០០៧ -អនុក្រឹត្យ លេខ ៩១៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥២៦៥

១៥-១១-២០០៧ -អនុក្រឹត្យ លេខ ៩១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥២៦៦

១៦-១១-២០០៧ -អនុក្រឹត្យ លេខ ៩២០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៥២៦៧

IV-ការងារបណ្តាក្រសួង

១-នីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១-ប្រកាសណែនាំ

០៦-១១-២០០៧ -ប្រកាសណែនាំ លេខ ១១៩៩ សហវ.ថ ស្តីពីការបិទបញ្ជីចំណូល-ចំណាយ និងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាជូនឆ្នាំ ២០០៧ ៥២៦៩

២-សេចក្តីណែនាំ

២៩-១០-២០០៧ -សេចក្តីណែនាំ លេខ ០០៩ សហវ ស្តីពីការប្រើប្រាស់គណនីរដ្ឋនៅតាមប្រព័ន្ធធនាគាររបស់ក្រសួង-ស្ថាប័ន មន្ទីរ-អង្គភាព និងសាលាខេត្ត-ក្រុង ៥២៨០

២-នីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាស

១២-៩-២០០៧ -ប្រកាសលេខ ០៣១ អបស/ម.ព ស្តីពីការផ្តល់វិញ្ញាបនបត្រទទួលស្គាល់ការរួមចំណែកអនុវត្តកែលំអគុណភាពសេវារបស់មន្ទីរពេទ្យ និង មណ្ឌលសុខភាព តាមរយៈឧបករណ៍វាយតម្លៃកីតៃ ១ ជំហានទី ១ ៥២៨២

៣-នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូស្គូ អ៊ុនជីនារីង & ខនស្ត្រាក់សិន ខូ អិលធីឌី** ៥២៨៧

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួល ស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាវស គ្រុប ខូ អិលធីឌី** ៥២៨៨

គ

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣៦ ពណ.នតក ស្តីពីការថុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រាម រ៉ូយ៉ាល់ រីហ្សត** ៩២៩០

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន **នេត អាយ ស៊ីលូសិន ធីធីអុី អិលធីឌី** ៩២៩២

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃាត់ខេនា លែន លីមីធីត** ៩២៩៣

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៣៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ.អុី.ឌី.ស៊ី ខូ អិលធីឌី** ៩២៩៤

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា សៅ_អុីស្ត អេចេន្ជា អុីន** ៩២៩៦

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ប៉ាក អុីនធើឆេនមេន សេនធ៍ ខូ អិលធីឌី** ៩២៩៨

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីផក អុិនវេសមេន** ៩៣០០

២១-៣-២០០៧ -លិខិតបញ្ជាក់លេខ ១១៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ា ហ៊ី** ៩៣០២

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៧០

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៤ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០០៤/០០៦ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់វិសោធនកម្មច្បាប់ ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងបន្តថ្នាក់ដឹកនាំការិយាល័យរដ្ឋបាល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ :

១-ឯកឧត្តម **ស៊ាន ទិត្យសុទ្ធ** ជាប្រធានការិយាល័យរដ្ឋបាល

២-ឯកឧត្តម **ទែម ក្រាញ់តូនី** ជាប្រធានការិយាល័យរដ្ឋបាលបម្រុង

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរល. ០៧១១. ៥៩៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៣៧ ច.ល

[illegible] ចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៧

[illegible]រាជរដ្ឋាភិបាល

[illegible] **ជិនកេន**

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម ពេជ្រ សំណាង ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវ ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៨៧.០៧១១.៦០០

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ ៣៩០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ ១១ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/១១០៧/៥៧៥

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២00៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានៈឯកឧត្តម ម៉ិន និ ជាអគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១១.៦០៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ:៥៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
... ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតភូមិជាតិសាសនា រតនត្តយ៉ា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១-ឯកឧត្តម **ស៊ិន ម៉េងស្រ៊ុន** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ

២-ឯកឧត្តម **ព្រហ្ម សិទ្ធិត្រា** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១១.៦០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

លេខ: ៥៥៧ច.ល
...ចម្លងចែក
...ថ្ងៃទី... ខែ វិច្ឆិកា ឆ្នាំ២០០៧
...រាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៧/៥៧៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១-ឯកឧត្តម ឈី នុជ	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប បន្ថែមលើមុខងារបច្ចុប្បន្ន
២-ឯកឧត្តម ហង់ ជួនណារ៉ុន	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប បន្ថែមលើមុខងារបច្ចុប្បន្ន
៣-ឯកឧត្តម ឌី ចន្ទ្រផល	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប បន្ថែមលើមុខងារបច្ចុប្បន្ន
៤-ឯកឧត្តម ទី សុគន្ធ	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប បន្ថែមលើមុខងារបច្ចុប្បន្ន
៥-ឯកឧត្តម ណៅ ធូក	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប បន្ថែមលើមុខងារបច្ចុប្បន្ន
៦-ឯកឧត្តម ស៊ី ឈុំម៉ុន	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប បន្ថែមលើមុខងារបច្ចុប្បន្ន
៧-ឯកឧត្តម កែវ សុខឃាង	ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE

៨-ឯកឧត្តម ស៊ុយ ថេងឈួន ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៩-ឯកឧត្តម ឡុង ម៉ាន ជាទីប្រឹក្សាអមអាជ្ញាធរអាងទន្លេសាប មានឋានៈស្មើ **អគ្គនាយក**។

មាត្រា ២ : ត្រូវបានតែងតាំង :

១-ឯកឧត្តម ម៉ី សាំងអេង ជាអគ្គលេខាធិការ នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម ចាយ ម៉ារិន ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣-ឯកឧត្តម ឃុន សុគ្រីន ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៤-ឯកឧត្តម ឡុង ឈាង ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៥-ឯកឧត្តម សៅ សុគាត ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៦-ឯកឧត្តម សុខ គាង ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៧-ឯកឧត្តម មាស អឿន ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៨-ឯកឧត្តម ស្រី ម៉ាង ជាអគ្គលេខាធិការរង នៃអាជ្ញាធរអាងទន្លេសាប
មានឋានៈស្មើ **អគ្គនាយក**។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមលាយព្រះហស្តលេខា

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ចបត.០៧១១.៦០៦

លេខ: ៥៤៧ច.ល
ដើម្បីចម្លងចែកចាយ
ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ : ១៣៣/០០៥/២០០៧

ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សេចក្តីសម្រេច

លេខ : ០៩៣/០០៨/២០០៧ កបធ.ច

ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ សម្រេចលុបឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៃឃុំរការកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល (ដូចមានបញ្ជីរាយនាមភ្ជាប់ជាមួយ)

- បានឃើញពាក្យបណ្តឹងរបស់លោក **អោន គីមលាន** ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូង នៅការិយាល័យលេខ ០៦៥៤ ឃុំកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ០៨:៣០ នាទី
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ របស់លោក **អោន គីមលាន** សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១០:៣០ នាទី

ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍
ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក **អោន គីមលាន** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលប្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា តាមគោលការណ៍នៃច្បាប់ ម្ចាស់បណ្តឹងមានសិទ្ធិសុំដកពាក្យបណ្តឹងរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកបានគ្រប់ពេលវេលាទាំងអស់នៃនីតិវិធី ។

សម្រេច

មាត្រា ១. - ទទួលពាក្យបណ្តឹងរបស់លោក **អោន គីមលាន** ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០០៧ សុំដកពាក្យបណ្តឹង ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០០៧ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

មាត្រា ២. - តម្កល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ ដែលសម្រេចលុបឈ្មោះប្រជាពលរដ្ឋចំនួន ៥៦ នាក់ ចេញពីបញ្ជីបោះឆ្នោតដំបូងនៅការិយាល័យលេខ ០៦៥៤ ឃុំកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

មាត្រា ៣. - សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង គ្រប់ស្ថាប័នរបស់រដ្ឋ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ : ០០៣/០១/២០០៧ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សូមគោរពជូន

លោកជំទាវ ប្រធានគណៈកម្មការសិទ្ធិមនុស្ស

ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា នៃរដ្ឋសភា

កម្មវត្ថុ : អំពីសំណើសុំពិនិត្យធម្មនុញ្ញភាពផ្លូវច្បាប់រវាងខ្លឹមសារលិខិតលេខ ៥៨៨ ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និង សាលដីកាស្ថាពររបស់តុលាការកំពូល

យោង : លិខិតរបស់លោកជំទាវលេខ ៣៤៧ រស.គ១ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០០៧ ផ្ញើមកក្រុមប្រឹក្សាធម្មនុញ្ញ តាមរយៈសម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបលោកជំទាវប្រធានគណៈកម្មការថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលសំណើរបស់លោកជំទាវ និង បានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៧ ព្រមទាំងបានសម្រេចដូចតទៅ :

១-សំណើសុំពិនិត្យធម្មនុញ្ញភាពផ្លូវច្បាប់រវាងខ្លឹមសារលិខិតលេខ ៥៨៨ ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និង សាលដីកាស្ថាពររបស់តុលាការកំពូល មិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ

២-បុគ្គលស្នើសុំពិនិត្យធម្មនុញ្ញភាពពុំមានគុណវុឌ្ឍិស្របតាមមាត្រា ១៤១ថ្មី នៃរដ្ឋធម្មនុញ្ញទេ

៣-រឿងក្តីទាំងអស់ រួមទាំងរឿងក្តីដូចពោលផង ស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការ ។

សូមលោកជំទាវប្រធានគណៈកម្មការទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។៚

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩១៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ / ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៣០០ / ១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក. ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តការផ្លាស់ប្តូរក្របខ័ណ្ឌឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស ម្រេ ច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **តូច សុវណ្ណា** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានបច្ចេកទេសថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩១៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ស ម្រេ ច

មាត្រា ១.– ត្រូវបានប្រគល់ភារកិច្ចជូនលោកស្រី **ពាន សុខុនណារ៉ា** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២.– បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣.– រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៧

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...[illegible] អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ជា ពិសី** ជាសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម :

១-វរសេនីយ៍ទោ **ម៉ាន់ ចំនួនឡូនា** អត្តលេខ ០២៩១៨៤ សិក្សាការបញ្ជប់ វគ្គសេនាធិការ ប្រទេសម៉ាឡេស៊ី

២-វរសេនីយ៍ទោ **ចាន់ សារឿន** អត្តលេខ ០០១៤៨០ សិក្សាការបញ្ចប់ វគ្គសេនាធិការ ព្រះរាជាណាចក្រថៃឡង់ដ៍

៣-វរសេនីយ៍ទោ ឈឹម ចេង អត្តលេខ ០០៨៤៩៩ សិក្ខាកាមបញ្ចប់ វគ្គបណ្តុះឯកទេស

កិរិតទី១ សាធារណៈរដ្ឋសង្គមនិយមវៀតណា

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្ សមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៥៥ ស.ហ.វ-ប្រក

បានទទួល
ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ប្រកាសណែនាំ

ស្តីពី

ការបិទបញ្ជីចំណូល-ចំណាយ និង ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៧

- យោងច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និង ច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- យោងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- យោងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- យោងអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- យោងអនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងអនុក្រឹត្យលេខ ១៧១ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- យោងប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាទូទៅរបស់រដ្ឋ ។

ដោយឆ្នាំថវិកាត្រូវចាប់ផ្តើមពីថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ (មាត្រា ៤ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីនីតិវិធីបច្ចេកទេសដើម្បីធានាឱ្យការបិទបញ្ជីចំណូល-ចំណាយនិងការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧ ប្រព្រឹត្តទៅបានត្រឹមត្រូវ និង ទាន់ពេលវេលា ដូចតទៅនេះ :

I-អំពីការបិទបញ្ជីចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧

ក-អំពីចំណូលថវិការដ្ឋ

ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធដកចំណូលយកទៅចំណាយតាមទំនើងចិត្ត ឬមួយពន្យារពេលបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ (ភាគទី III និង មាត្រា១០៦ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥)។ ដូចនេះ **ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ជាកំហិត** ។

ខ-អំពីចំណាយថវិការដ្ឋ

ការបិទបញ្ជីចំណាយ (មាត្រា ១០៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ត្រូវដំណើរការទៅតាមដំណាក់កាលចំណាយ និង ពេលវេលាដូចតទៅ :

* **ទិដ្ឋាការនៃការសន្យាចំណាយ** ក្រៅពីចំណាយបៀវត្ស និង ចំណាយសំរាប់គោលនយោបាយសង្គមកិច្ច **មិនអាចអនុវត្តក្រោយថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បានទេ** (មាត្រា ១០៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥) លើកលែងក្នុងករណីមាន**ចំណាយចាំបាច់មិនអាចខានបាន និង មានឥណទានថវិកាសល់ទំនេរ** ហើយទិដ្ឋាការនេះត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (មាត្រា ២០ នៃអនុក្រឹត្យលេខ ៨១ អនក្រ. បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) តែក៏**មិនឱ្យហួសពីថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៧ ដែរ** ។

* **រាល់ការសន្យាចំណាយដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ត្រូវបានបដិសេធចោល ហើយត្រូវស្នើសុំធានាចំណាយជាថ្មី ដោយប្រើប្រាស់ឥណទានថវិកានៃឆ្នាំបន្ទាប់** (មាត្រា ១០៩ នៃ អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។

* រតនាគារជាតិ និងរតនាគារខេត្ត-ក្រុង **ត្រូវបញ្ឈប់ការទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧** លើកលែងអាណត្តិប្រាក់បៀវត្ស និង ប្រាក់គោលនយោបាយសង្គមកិច្ច និង អាណត្តិនិយ័តកម្ម (មាត្រា១១១ អនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥)។ ដូច្នេះ ក្រសួង-ស្ថាប័នត្រូវប្រមូលសក្ខីប័ត្រ និង លិខិតយុត្តិការដែលបញ្ជាក់ពីសេវាដែលបានធ្វើរួច **ដើម្បីរៀបចំអាណត្តិបើកប្រាក់ ហើយបញ្ជូនទៅស្នើសុំទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ**

ឆ្នាំ ២០០៧ ។ ដោយឡែកមន្ទីរជំនាញខេត្ត-ក្រុង ត្រូវបញ្ជូនអាណត្តិបើកប្រាក់ដែលបានឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ **ទៅរតនាគារ ខេត្ត-ក្រុងពិនិត្យចុះបញ្ជីគណនេយ្យ ឱ្យបានមុនថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៧** ។

គ-អំពីចំណាយរដ្ឋទេយ្យបុរេប្រទាន និង ថវិកាបុរេប្រទាន

* **រដ្ឋទេយ្យករបុរេប្រទានត្រូវប្រមែប្រមូលលិខិតយុត្តិការចំណាយ** ដើម្បីធ្វើអាណត្តិនិយ័តកម្ម(ទូទាត់) **យ៉ាងយូរបំផុតក្នុងរយៈពេលមួយខែ** ដោយគិតចាប់ពីកាលបរិច្ឆេទដកសាច់ប្រាក់ពីរតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង (មាត្រា ៦៧ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩) លើកលែងតែក្នុងខែធ្នូនៃឆ្នាំ រតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង **ត្រូវបញ្ឈប់ការដកសាច់ប្រាក់ចុងក្រោយបង្អស់ពីគណនីរដ្ឋទេយ្យបុរេប្រទាន នៅម៉ោង ១៧ និង ៣០នាទី នាថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៧** ។ ក្នុងរយៈពេលពីថ្ងៃទី ១១ ដល់ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៧ រដ្ឋទេយ្យករបុរេប្រទាន ត្រូវរៀបចំប្រមូលឯកសារ និង លិខិតយុត្តិការចំណាយ ដើម្បីធ្វើអាណត្តិនិយ័តកម្មឆ្លងទិដ្ឋាការ រួចបញ្ជូនទៅរតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង **ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧** ជាកំហិត ។

* **ថវិកាបុរេប្រទាន** គឺជាការបើកផ្តល់ចំណាយមុនដែរ ក្នុងករណីមានការចាំបាច់បន្ទាន់ ដូច្នេះការផ្តល់ថវិកាបុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ហើយការទូទាត់ថវិកាបុរេប្រទាននេះ ក៏ត្រូវរៀបចំប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី **៣១ ខែ ធ្នូ ឆ្នាំ ២០០៧** ដោយគិតរួមទាំងចំណាយថវិកាបុរេប្រទានជារូបិយប័ណ្ណអន្តរជាតិ ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានផ្តល់ជូនតាមរយៈមូលប្បទានប័ត្រ ។ **ក្នុងករណីប្រាក់បុរេប្រទាន ឆ្នាំ ២០០៧ មិនត្រូវបានធ្វើការទូទាត់ឱ្យជម្រះស្រឡះទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងកាត់ទុកឥណទានថវិកាពាក់ព័ន្ធក្នុងក្របខ័ណ្ឌថវិកាឆ្នាំ ២០០៨ មុននឹងផ្តល់ធានាចំណាយសំរាប់ឆ្នាំ ២០០៨** ។

ក្នុងករណីមានការខ្វះខាតឥណទានថវិកាសំរាប់ធ្វើការទូទាត់រដ្ឋទេយ្យបុរេប្រទាន ឬ បុរេប្រទានរដ្ឋទេយ្យករ ត្រូវរាយការណ៍ជាបន្ទាន់ទៅអាណាប័ក ដើម្បីមានវិធានការតាមការជាក់ស្តែង ជាអាទិ៍ :

- លើកសំណើសុំនិយ័តភាពថវិកាផ្ទៃក្នុងដែលសល់ទំនេរមកបំពេញឱ្យខ្ទង់ថវិកាដែលត្រូវធ្វើអាណត្តិនិយ័តកម្ម ក្នុងនោះគិតរួមទាំងប្រាក់បុរេប្រទានឆ្នាំមុន១ផងដែរ ។
- កាត់បន្ថយ ឬ ផ្អាកជាបណ្តោះអាសន្ននូវទឹកប្រាក់បានធានាចំណាយមួយចំនួន ដែលមិនសូវចាំបាច់ សំដៅធ្វើការជំរះបញ្ជីចំណាយថវិការដ្ឋទេយ្យបុរេប្រទាន ឬ បុរេប្រទាន ឱ្យបានជ្រះស្រឡះ ។

ឃ-អំពីចលនាឥណទាន

ការធ្វើ**និយ័តភាពថវិកា**ផ្ទៃក្នុងជំពូកសំរាប់ការទូទាត់ចំណាយចាំបាច់ ឬ ទូទាត់រដ្ឋទេយ្យបុរេប្រទាន ឬ ទូទាត់បុរេប្រទាន **ត្រូវបញ្ឈប់នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧** ។ ដូច្នេះក្រសួង-ស្ថាប័ន និង មន្ទីរជំនាញតាមខេត្ត-

ក្រុងទាំងអស់ ត្រូវបញ្ជូនសំណុំលិខិតស្នើសុំនិយ័តភាពឥណទាន មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **យ៉ាងយូរត្រឹមថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧** ។

ខ. កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារ

កិច្ចប្រតិបត្តិការនិយ័តកម្មនៃរតនាគារសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ត្រូវបន្តរហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ (មាត្រា ១១១ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥) ។ កិច្ចប្រតិបត្តិការនេះ ត្រូវពិនិត្យកត់ត្រាជាលេខនាបន្ថែម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលទាក់ទងទៅនឹង :

* ការកត់ត្រាជាស្ថាពរនៃចំណូល ឬ ចំណាយដែលបានពិនិត្យកត់ត្រាជាលេខនាមុនថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៧ ជាអាទិ៍ ចូលគណនីកត់ត្រាបណ្តោះអាសន្ន ។
* អាណត្តិនិយ័តកម្មដែលទាក់ទងដល់ចំណាយដែលបានទូទាត់ដោយរជ្ជទេយ្យបុរេប្រទាន និងបុរេប្រទាន មុនថ្ងៃទី ៣១ ខែ ធ្នូ ។
* ការកែតម្រូវលេខនាខុស ។
* កិច្ចប្រតិបត្តិការប្រមូលកិច្ចការគណនេយ្យករនៃអង្គភាពរដ្ឋបាលហិរញ្ញវត្ថុ និង គណនេយ្យកររងនៃរតនាគារខេត្ត-ក្រុង ។

គ. កិច្ចប្រតិបត្តិការថវិកាឆ្នាំ ២០០៨

១- ក្នុងករណីមានភាពប្រញាប់លើឥណទាននៃឆ្នាំបន្ទាប់ (២០០៨) ក្នុងអំឡុងខែ ធ្នូ ឆ្នាំ ២០០៧ អនុញ្ញាត អោយក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត-ក្រុង ស្នើសុំធានាចំណាយថវិកា សំរាប់ឆ្នាំ ២០០៨ មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មកមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់មន្ទីរជំនាញខេត្ត-ក្រុង ដោយឈរលើមូលដ្ឋាន ១/១២ នៃឥណទានប្រចាំឆ្នាំ ២០០៧ ។

២- គំរោងស្នើសុំធានាចំណាយត្រូវធ្វើឡើងចំពោះតែមុខទំនិញ សេវា ឬ ការជួសជុលថែទាំទាំងឡាយណាដែលមានតំរូវការចំណាយថវិកាច្រើន និង មានតំរូវការជាបន្ទាន់នូវការផ្គត់ផ្គង់ទំនិញ សេវា ឬ ការជួសជុលថែទាំនៅដើមឆ្នាំ ២០០៨ ។

៣- ចំពោះការធានាចំណាយថវិកាជាបន្តបន្ទាប់ទៀត ដែលត្រូវអនុវត្តក្នុងអំឡុងឆ្នាំថវិកា នឹងត្រូវផ្តល់ជូនក្រោយពីការតម្រឹមផ្ទៀងផ្ទាត់ជាមួយឥណទានថវិកា ដែលត្រូវបានអនុម័តយល់ព្រមដោយអង្គការនីតិបញ្ញត្តិ ។

៤- ចាប់ពីថ្ងៃទី ០១ ខែ **មករា ឆ្នាំ ២០០៨** តទៅ រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋ ឆ្នាំថ្មី **ត្រូវកត់ត្រាចូលក្នុងគណនីថវិការដ្ឋឆ្នាំ ២០០៨** ។ ដោយឡែក ចំពោះប្រាក់បៀវត្សដែលនៅសល់ពីឆ្នាំចាស់ (២០០៧) ហើយយកមកបង់ចូលនៅក្នុងឆ្នាំ ២០០៨ ត្រូវចាត់ទុកថាជាសំណេះចំណាយ ដោយកត់ត្រាបន្ថយលើខ្ទង់ចំណាយ ដែលមានការពាក់ព័ន្ធ ។

៥- រាល់កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាឆ្នាំ ២០០៨ ត្រូវផ្អែកលើកម្មវិធីចំណូល-ចំណាយ ប្រចាំខែ និង ត្រីមាស ដែលក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំ និង ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ក្នុងរយៈពេល ០២ សប្តាហ៍ ក្រោយពីច្បាប់ថវិកាត្រូវបានអនុម័ត ។

II-ការធ្វើរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧

ការបូកសរុបសម្រេចអំពីការអនុវត្តថវិកាទូទៅរបស់រដ្ឋឆ្នាំ ២០០៧ ត្រូវដំណើរការដូចតទៅ :

* ចាប់ពីថ្ងៃទី **០១ ខែ កុម្ភៈ ឆ្នាំ ២០០៨** រតនាគារជាតិ ត្រូវដំណើការបូកសរុបកិច្ចប្រតិបត្តិការរតនាគារទូទាំងប្រទេស អំពីការអនុវត្តចំណូល-ចំណាយថវិការដ្ឋឆ្នាំ ២០០៧ ព្រមទាំងធ្វើតារាងតុល្យភាពគណនីជាស្ថាពរ **យ៉ាងយូរត្រឹមថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៨** ។

* ចាប់ពីថ្ងៃទី **០១ ខែ មករា ឆ្នាំ ២០០៨** គ្រប់មន្ទីរជំនាញខេត្ត-ក្រុង ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយរបស់អង្គភាពខ្លួនឱ្យបានត្រូវគ្នាជាមួយរតនាគារខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួន រួចផ្ញើមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងសាមី **ឱ្យបានមុនថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨** ។

* មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចបូកសរុបអនុវត្តចំណូល-ចំណាយ របស់មន្ទីរជំនាញនៅខេត្ត-ក្រុងដែលបានផ្ទៀងផ្ទាត់ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រតនាគារជាតិ និង នាយកដ្ឋានថវិកា) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ជាកំហិត** ។

* ចំពោះក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាលត្រូវផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល-ចំណាយថវិការបស់ខ្លួនជាមួយរតនាគារជាតិ នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ (ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស) និង មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីឱ្យបានត្រូវគ្នា ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណូល-ចំណាយថវិការបស់ក្រសួង-ស្ថាប័នខ្លួន ដោយមានបញ្ចូលចំណូល-ចំណាយថវិការបស់មន្ទីរជំនាញនានាក្រោមឱវាទនៅតាមខេត្ត-ក្រុង រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (រតនាគារជាតិ និង នាយកដ្ឋានថវិកា) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ជាកំហិត** ។

* ចំពោះចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស ក្រសួង-ស្ថាប័ន ត្រូវផ្ទៀងផ្ទាត់តួរលេខអនុវត្តជាមួយអង្គភាពគ្រប់គ្រងគំរោងរបស់ក្រសួង-ស្ថាប័ននីមួយៗ ហើយរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណាយវិនិយោគប្រចាំឆ្នាំ ២០០៧ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និង នាយកដ្ឋានថវិកា) **ឱ្យបានមុនថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨ ជាកំហិត** ។

ក្រសួង-ស្ថាប័ន រដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួន ទៅតាមតារាងគំរូដែលមានភ្ជាប់មកជាមួយនេះ ឱ្យបានតាមកាលកំណត់ខាងលើជាកំហិត ដើម្បីឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានលទ្ធភាពធ្វើការបូកសរុបរៀបចំសេចក្តីព្រាង

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ សំរាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសម្រេច និង ស្ថាប័ននីតិបញ្ញត្តិអនុម័ត ឱ្យបានទាន់ពេលវេលា ។

ក្នុងករណីក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល មន្ទីរជំនាញខេត្ត-ក្រុង និង មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុណា ផ្ញើរបាយការណ៍បូកសរុបអនុវត្តថវិការបស់ខ្លួនមិនបានទាន់ពេលវេលាកំណត់ខាងលើទេ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងផ្អែកតាមតួលេខរបាយការណ៍បូកសរុបរបស់រតនាគារជាតិជាផ្លូវការ ។

គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល រតនាគារជាតិ រតនាគារខេត្ត-ក្រុង មន្ទីរជំនាញខេត្ត-ក្រុង និង នាយកដ្ឋានពាក់ព័ន្ធទាំងឡាយ ត្រូវអនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូនៈ</u>

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អាជ្ញាធរសវនកម្មជាតិ
(ដើម្បីជូនជ្រាបជាព័ត៌មាន)
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
-គ្រប់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល
-នាយកដ្ឋានហិរញ្ញកិច្ច
-នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ
-នាយកដ្ឋានសវនកម្មផ្ទៃក្នុង
-នាយកដ្ឋាននីតិកម្ម
-នាយកដ្ឋានវិនិយោគ និង សហប្រតិបត្តិការ
-នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ
-នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ
-នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន
-រតនាគារជាតិ
-គ្រប់អភិបាលខេត្ត-ក្រុង
-មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង
-រតនាគារខេត្ត-ក្រុង
-គ្រប់មន្ទីរជំនាញតាមខេត្ត-ក្រុង
(ដើម្បីអនុវត្ត)
-ឯកសារនិងកាលប្បវត្តិ

ក្រសួង:......................

តារាងសរុបចំណូលថវិកាជាតិ
សម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ១

ជំពូក	គណនី	អនុគណនី	បរិយាយ	ច្បាប់ហិរញ្ញវត្ថុ ដើមឆ្នាំ	អនុវត្តជាក់ស្តែង	សមមាត្រ ប្រៀបធៀប	ផ្សេងៗ
				១	២	៣=២/១	-
			I -ផ្នែករដ្ឋបាលកណ្តាល				
			II-ផ្នែកមន្ទីរជំនាញខេត្ត-ក្រុង				
			សរុបរួម				

ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា	ហត្ថលេខា	ហត្ថលេខា
ប្រធានរតនាគារជាតិ	រដ្ឋមន្ត្រី	ប្រធានគណនេយ្យ	អ្នកធ្វើតារាង

ក្រសួង:.....................

តារាងសរុបចំណាយថវិការដ្ឋ
សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

តារាងទី ២

